# សេចក្ដីប្រកាសព័ត៌មានរវាងក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និង អង្គការសុខភាពពិភពលោក
# ករណីទី៨នៃជំងឺផ្ដាសាយបក្សីនៅលើមនុស្សក្នុងប្រទេសកម្ពុជា
# ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៨

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសូមបញ្ជាក់ថា បុរសម្នាក់អាយុ១៩ឆ្នាំគឺជាមនុស្សទី៨ហើយដែលកើតជំងឺផ្ដាសាយបក្សីនៅប្រទេសកម្ពុជាចាប់តាំងពីដើមឆ្នាំ ២០០៥ មក។ នេះជាករណីទី១នៃជំងឺផ្ដាសាយបក្សីដែលបានរកឃើញនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ២០០៨។ អ្នកជំងឺរស់នៅស្រុកកណ្ដាលស្ទឹងខេត្ត កណ្ដាល ។

អ្នកជំងឺចាប់ផ្ដើមឈឺ ដោយមានអាការៈ ក្ដៅខ្លួន ក្អក ឈឺសាច់ដុំ និង ឈឺបំពង់ក នៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០៨ ហើយបានទៅរកពេទ្យព្យាបាលនៅគ្លីនិច និង មណ្ឌលសុខភាពក្នុងតំបន់ដែលគាត់រស់នៅ នៅថ្ងៃទី ៣០ ខែវិច្ឆិកា និង ម្ដងទៀតនៅថ្ងៃទី ២ ខែធ្នូ។ អ្នកជំងឺត្រូវបានរកឃើញតាមរយៈប្រព័ន្ធតាមដានរកជំងឺគ្រុនក្ដៅស្រួច ហើយការស្រាវជ្រាវមួយនេះត្រូវបានធ្វើនៅក្នុងខេត្តកណ្ដាល និង ដែលមានការបញ្ជាក់ពីផ្នែកមន្ទីរពិសោធន៍ដែលត្រូវបានធ្វើឡើងដោយមជ្ឈមណ្ឌលជាតិ ជំងឺផ្ដាសាយ នៅភ្នំពេញ នៅថ្ងៃទី ១១ ខែ ធ្នូ ។

បច្ចុប្បន្ននេះអ្នកជំងឺកំពុងទទួលការព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្រក្នុងទីក្រុងភ្នំពេញ ។ ក្រុមអង្កេតស្រាវជ្រាវ ដែលដឹកនាំដោយក្រសួងសុខាភិបាល កំពុងស្ថិតនៅកន្លែងកើតហេតុដើម្បីកំណត់អ្នកដែលបានប៉ះពាល់ ជាមួយនឹងអ្នកជំងឺហើយចាប់ផ្ដើមធ្វើការព្យាបាល និង ការពារ ។ ក្រសួងសុខាភិបាលនឹងបន្តចុះទៅតាមផ្ទះនិមួយៗក្នុងតំបន់ដែលមានការប៉ះពាល់ដើម្បីស្វែងរកអ្នកដែលមានអាការៈ ក្ដៅខ្លួន ក្អក និង បានប៉ះពាល់ជាមួយមាន់ដែលឈឺ ឬ ងាប់ ។ សំភារៈសំរាប់អប់រំសុខភាពក៏នឹងត្រូវបានធ្វើការចែកចាយផងដែរ ។

ក្រសួងកសិកម្មកំពុងតែដឹកនាំការស្រាវជ្រាវលំអិតអំពីការស្លាប់របស់បសុបក្សីនៅក្នុងតំបន់ជុំវិញភូមិនោះ ។

នេះគឺជាករណីទី៨នៃជំងឺផ្ដាសាយបក្សីលើមនុស្ស ដោយវីរុស H5N1 ដែលត្រូវបានបញ្ជាក់ក្នុងប្រទេសកម្ពុជា ។ ករណីចំនួន ៧ ពីមុនមកត្រូវបានស្លាប់ទាំងអស់ និង ករណីចុងក្រោយកើតឡើងនៅក្នុងខែ មេសា ឆ្នាំ ២០០៧ ។ នៅលើពិភពលោកមាន ៣៨៩ ករណី ជំងឺផ្ដាសាយបក្សីលើមនុស្ស ដែលបង្កឡើងដោយវីរុស H5N1 ហើយ ក្នុងនោះ ២៤៦ ករណីត្រូវបានស្លាប់ ។

.....................................


***សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង:***

***ក្រសួងសុខាភិបាល:***

***វេជ្ជបណ្ឌិត សុខ ទូច*** ទូរស័ព្ទលេខ: +៨៥៥ (0) ១២ ៨៥៦ ៨៤៨ ឬ

***វេជ្ជបណ្ឌិត លី សូវ៉ាន់*** ទូរស័ព្ទលេខ +៨៥៥ (0) ១២ ៨២៥ ៤២៤

***អង្គការសុខភាពពិភពលោក:***

***វេជ្ជបណ្ឌិត ម៉ៃឃើល អូលៀរី*** ទូរស័ព្ទលេខ: +៨៥៥ (0) ១២ ៩៧៦ ៩៧៦ ឬ

***វេជ្ជបណ្ឌិត នីម៉ា អាសហ្គារី*** ទូរស័ព្ទលេខ: +៨៥៥ (0) ១២ ៤៤៣ ៨៧៧